# តើបុណ្យអ៊ីស្ទើរគឺជាអ្វី ?



បុណ្យអ៊ីស្ទើរគឺជាពេលដ៏ពិសេសមួយ ដើម្បីគិតអំពីព្រះយេស៊ូវគ្រីស្ទ ។



នៅបុណ្យអ៊ីស្ទើរ យើងចងចាំថា ព្រះយេស៊ូវជ្រាបដឹងអំពីអារម្មណ៍របស់យើង ។ ទ្រង់យល់រាល់ការឈឺចាប់ និងទុក្ខព្រួយទាំងអស់របស់យើង ។



ព្រះយេស៊ូវសុគតនៅលើឈើឆ្កាង ពីព្រោះទ្រង់ស្រឡាញ់យើង ។ ព្រះសពរបស់ទ្រង់ត្រូវបានដាក់នៅក្នុងផ្នូរមួយ ។



បីថ្ងៃក្រោយមក ផ្នូរនោះនៅទទេ ។ ព្រះយេស៊ូវមានព្រះជន្មរស់ឡើងវិញម្ដងទៀត ! យើងហៅការណ៍នេះថា ការរស់ឡើងវិញ ។

ដោយសារព្រះយេស៊ូវគ្រីស្ទ នោះយើងក៏នឹងរស់ឡើងវិញម្ដងទៀតផងដែរបន្ទាប់ពីយើងស្លាប់ ។ យើងអាចមានអារម្មណ៍នៃក្ដីស្រឡាញ់មកពីព្រះវរបិតាសួគ៌ និងព្រះយេស៊ូវជារៀងរាល់ថ្ងៃ មិនមែនត្រឹមតែនៅថ្ងៃបុណ្យអ៊ីស្ទើរប៉ុណ្ណោះទេ !